លេខ ៧ ឆ្នាំ ២០១៧ | Issue 7 year 2017

CAMBODIA RICE FEDERATION

# ព្រឹត្តិបត្រព័ត៌មាន

## "ដាំស្រូវអោយត្រូវទីផ្សារ"






# មាតិកា


1 វិចារណកថារបស់ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ........ ២-៣

2 បេសកកម្មស្វែងរកទីផ្សារក្រៅប្រទេស និង និន្នាការប្រែប្រួល ........ ៤

2.1 ទីផ្សារអឺរ៉ុប ........ ៥-៧

2.2 ទីផ្សារចិន ........ ៨-១០

2.3 ទីផ្សារផ្សេងៗទៀត ........ ១១

3 សកម្មភាពសម្របសម្រួលបែបបទចូលទីផ្សារ ........ ១២

3.1 ចុះបញ្ជីម៉ាកពាណិជ្ជកម្ម ........ ១២-១៣

3.2 ផ្សព្វផ្សាយលក្ខខណ្ឌដល់ក្រុមហ៊ុននាំចេញ ........ ១៤-១៥

3.3 សម្រួលការចុះត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានកសិកម្ម (GDA) ទៅលើរោងម៉ាស៊ីនកិនស្រូវជាសមាជិក ........ ១៥-១៦

4 តំរង់ការផលិតស្រូវតម្រូវទីផ្សារ ........ ១៧-២១

5 ទស្សនៈក្នុងវិស័យស្រូវអង្ករ ........ ២២-២៣

6 តួលេខ និង កម្រងរូបភាព ........ ២៤-៣០

7 អំពីសមាជិកភាព ........ ២៨-២៩



CAMBODIA RICE FEDERATION

ចេញផ្សាយដោយ

**សហពន្ធ័ស្រូវអង្ករកម្ពុជា**

និពន្ធ និងចងក្រងដោយ

ក្រុមការងារលេខាធិការដ្ឋានសហពន្ធ័ស្រូវអង្ករកម្ពុជា



គេហទំព័រ៖ www.crf.org.kh

សារអេឡិចត្រូនិក៖ info@crf.org.kh

ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៥៥៩ ៨៩៩៩
+៨៥៥ (0) ៨៧ ៥៥៩ ៨៩៩



**ឧបត្ថម្ភដោយ**

SMWaypoint PRECISION REMOTE SENSING

Nikoline investment co. ltd

ANZ Royal



អាសយដ្ឋាន៖ អគារពាណិជ្ជកម្មសូម៉ា ជាន់ទី ៧ អាគារលេខ ២C ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មី II ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

# សាររបស់ ឯកឧត្តម សុខ ពុទ្ធីវុធ  ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

*"ដាំស្រូវអោយត្រូវទីផ្សារ"*



ការធ្វើទំនើបកម្មនិងការបង្កើននូវភាពប្រកួតប្រជែងប្រកបដោយនិរន្តរភាពគឺមានសារៈសំខាន់ណាស់សម្រាប់អនាគតរបស់វិស័យស្រូវអង្ករកម្ពុជាដែលនេះនឹងចូលរួមដល់ការរីកចម្រើននៃសេដ្ឋកិច្ចជាតិពិសេសដល់ការលើកស្ទួយកម្រិតជីវភាពរបស់ ប្រជាជននៅជនបទ។ ដើម្បីសម្រេចនូវគោលដៅនេះយើងទាំងអស់គ្នាចាំបាច់ត្រូវយកចិត្តទុកដាក់ដល់ការពង្រឹងសង្វាក់ផលិតកម្មស្រូវអង្ករអោយបានរឹងមាំចាប់តាំងពីទឹកដីពូជឡសម្ងួតឃ្លាំងស្តុកនិងទីផ្សារ។

បរិមាណផលិតផលស្រូវរបស់កម្ពុជាមានចំនួនកើនឡើងនៅប៉ុន្មានឆ្នាំចុងក្រោយនេះដែលធ្វើអោយយើងមានសល់ស្រូវសម្រាប់កិនកែច្នៃជាអង្ករសម្រាប់នាំចេញជា៤លាន៥សែនតោនសមាមាត្រនឹងបរិមាណអង្ករប្រមាណ ៣លានតោនអង្ករនៅឆ្នាំ២០១៦។ ប៉ុន្តែទោះជាយ៉ាងណាការនាំចេញអង្កររបស់យើងនៅមានកម្រិតនៅឡើយដែលនេះគឺជាសក្តានុពលមួយសម្រាប់យើងត្រូវរៀបចំប្រព័ន្ធមួយអោយបានច្បាស់លាស់ដើម្បីស្រូបយកស្រូវដែលលើសពីតម្រូវការក្នុងស្រុកសម្រាប់កិនកែច្នៃសំដៅបង្កើនការនាំចេញអង្កររបស់យើងទៅទីផ្សារអន្តរជាតិ។ដើម្បីសម្រេចនូវគោលដៅនេះយើងបានធ្វើការផ្តោតសំខាន់លើការងារគន្លឹះមួយចំនួនដែលក្នុងនោះរួមមានៈ

១) ប្រព័ន្ធលំហូរព័ត៌មានផ្សារភ្ជាប់គ្នារវាងកសិករ អ្នកកែច្នៃ ទៅនឹងទីផ្សារ និងសម្រួលការធ្វើពាណិជ្ជកម្ម

២) ការចរចារជាមួយរាជរដ្ឋាភិបាលក្នុងការបន្ធូរបន្ថយលើបន្ទុកនៃថ្លៃដើម

៣) ការបន្សុទ្ធពូជស្រូវដែលត្រូវទីផ្សារ

៤) ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដើម្បីសម្រួលដល់ការប្រមូល សម្ងួតនិងស្តុកទុកស្រូវប្រកបដោយគុណភាព

៥) ការពង្រីកទីផ្សារ

សម្រាប់ប្រព័ន្ធប្រមូលនិងផ្សព្វផ្សាយព័ត៌មាននិងការដោះស្រាយបញ្ហាប្រឈមជូនសមាជិកក៏ដូចជាវិស័យស្រូវអង្ករទាំងមូលតាមរយៈក្រុមការងាររាជរដ្ឋាភិបាលនិងវិស័យឯកជនលើវិស័យស្រូវអង្ករ (ក្រុមការងារទី៩) សហព័ន្ធស្រូវអង្ករកម្ពុជាបាននាំមុខចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយបញ្ហាប្រឈមនានារបស់សមាជិក ដូចជាបញ្ហាតម្លៃអគ្គិសនី តម្លៃដឹកជញ្ជូន ពន្ធអាករ និងអត្ថប្រយោជន៍នានាផ្សេងទៀតសំដៅបង្កើននូវភាពប្រកួតប្រជែងរបស់អង្ករកម្ពុជា។ តាមរយៈក្រុមការងារទី៩ ក្រុមការងារថ្នាក់ខេត្តក៏ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៧នេះសម្រាប់ដោះស្រាយបញ្ហាប្រឈមស្រូវអង្ករនៅថ្នាក់ខេត្តផ្ទាល់ដោយមានការចូលរួមពីអាជ្ញាធរខេត្តនិងស្ថាប័នពាក់ព័ន្ធនានា។ ក្រុមការងារនេះមានសារៈសំខាន់ក្នុងការទទួលយកនូវព័ត៌មាននិងដោះស្រាយបញ្ហាប្រឈមនៅក្នុងបណ្តាខេត្តនិមួយៗ។ ជាមួយគ្នានេះយើងក៏បានរៀបចំរចនាសម្ព័ន្ធលេខាធិការដ្ឋានតាមខេត្ត ដែលជួយសម្រួលក្នុងការធ្វើការជាមួយសមាជិកការប្រមូលព័ត៌មានពីផលិតកម្មស្រូវនិងសហការជាមួយរាជរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍និង វិស័យឯកជនក្នុងការផ្តល់ការបណ្តុះបណ្តាលតាមរយៈសិក្ខាសាលានានាផងដែរ។ តាមរយៈក្រុមការងារនៅតាមមូលដ្ឋាននេះសហព័ន្ធស្រូវអង្ករកម្ពុជាកាន់តែធ្វើការយ៉ាងជិតស្និទ្ធនិងដោយផ្ទាល់ជាមួយសមាជិកនិងដោះស្រាយបញ្ហាបានទាន់ពេលវេលា។

លើសពីនេះទៅទៀតយើងក៏បានធ្វើការជាមួយស្ថាប័នស្រាវជ្រាវដៃគូអភិវឌ្ឍន៍និងវិស័យឯកជនដើម្បីជម្រុញដល់ផលិតកម្មពូជនិងការវិនិយោគលើឃ្លាំងនិងឡសម្ងួត។ ជាក់ស្តែងយើងបានធ្វើការជាមួយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មCARDI សហការជាមួយដៃគូអភិវឌ្ឍន៍អូស្ត្រាលីCAVAC លើការបន្សុទ្ធពូជស្រូវសែនក្រអូបនិងការបង្កាត់ពូជផ្ការំដួលដែលមិនប្រកាន់រដូវដែលអាចអោយកសិករយើងពង្រីកការដាំដុះពូជនេះអោយបានច្រើនតម្រូវទៅតាមទីផ្សារអន្តរជាតិ។

ក្រៅពីការផ្តោតលើពូជដែលមានគុណភាពនិងឆ្លើយតបទៅនឹងទីផ្សារយើងក៏បានធ្វើការផងដែរជាមួយនឹងការវិនិយោគឃ្លាំងជាមួយវិស័យឯកជនដោយយើងបានចុះអនុស្សរណៈយោគយល់គ្នាជាមួយភាគីចិនខេត្តជីលីនក្នុងការសិក្សានិងសាងសង់ឃ្លាំងស្តុកនិងឡសម្ងួតដើម្បីជួយដល់ការប្រមូលទិញស្រូវ ពីកសិករនៅរដូវចម្រូតដែលនាពេលកន្លងមកកសិករត្រូវលក់ស្រូវនៅក្នុងតម្លៃថោកដោយសារកង្វះឃ្លាំងនិងឡសម្ងួត។

ក្រៅពីពូជឃ្លាំងឡសម្ងួតយើងក៏បានផ្តោតផងដែរទៅលើទីផ្សារ។ យើងបានចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការស្វែងរកទីផ្សារ ដើម្បីចូលរួមក្នុងបេសកកម្មពាណិជ្ជកម្មនៅក្រៅប្រទេស ក៏ដូចជាពិព័រណ៍អន្តរជាតិនានា ដើម្បីផ្សព្វផ្សាយពីគុណភាពល្អឯកនៃអង្ករកម្ពុជាដែលគេទទួលស្គាល់នៅលើពិភពលោក។ ជាមួយគ្នាដែរ យើងក៏បានខិតខំពង្រីកទីផ្សារនាំចេញបន្ថែមទៀត ទាំងក្នុងនិងក្រៅតំបន់។ ជាក់ស្តែងថ្មីៗនេះកូតានាំចេញទៅប្រទេសចិនបានកើនឡើងជាបន្តបន្ទាប់ ដែលកើនពី១០ម៉ឺនតោននៅឆ្នាំ២០១៦ ដល់ ៣០ម៉ឺនតោន នៅឆ្នាំ២០១៨។ ម្យ៉ាងទៀត ក្រោយពីទទួលបាននូវជ័យលាភីអង្ករល្អជាងគេនៅលើពិភពលោកចំនួន៣ឆ្នាំជាប់ៗគ្នា កម្ពុជាក្រអូបប្រណីតកម្ពុជាកាន់តែត្រូវបានគេទទួលស្គាល់ទៅលើគុណភាពខ្ពស់នៅលើឆាកអន្តរជាតិ។ ដើម្បីងាយស្រួលក្នុងការផ្សព្វផ្សាយ ធ្វើទីផ្សារ និងធានានូវកេរ្តិ៍ឈ្មោះនៃអង្ករកម្ពុជាសហព័ន្ធស្រូវអង្ករកម្ពុជាបានរៀបចំបង្កើតនូវម៉ាកវិញ្ញាតកម្ម **(Certification Mark)** អង្ករក្រអូបប្រណីតរបស់កម្ពុជាមួយ ដែលនឹងមានឈ្មោះថា ម្លិះអង្គរ (MALYS ANGKOR)។ ជាមួយម៉ាកសញ្ញានេះ យើងសង្ឃឹមជឿជាក់ថានឹងមានការកើនឡើងនូវតម្រូវការអង្ករកម្ពុជានៅក្នុងទីផ្សារដែលនេះ នឹងជួយជម្រុញដល់ផលិតកម្មស្រូវសម្រាប់ការគាំទ្រដល់ម៉ាកសញ្ញានេះ ពិសេសការធានានូវទីផ្សារសម្រាប់កសិករកម្ពុជាតាមរយៈការធ្វើកសិកម្មតាមកិច្ចសន្យាជាដើម។

ការងារដែលសហព័ន្ធបានធ្វើគឺសំដៅកសាងនូវប្រព័ន្ធមួយសម្រាប់វិស័យស្រូវអង្ករដោយផ្សារភ្ជាប់ពីស្រែដល់អ្នកបរិភោគអង្ករពោលគឺ **ដាំស្រូវអោយត្រូវទីផ្សារ**។ យើងខ្ញុំជឿជាក់ថាការចូលរួមចំណែកពីសមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជាទាំងអស់គ្នាដោយមានកិច្ចសហប្រតិត្តិការពីរាជរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ស្ថាប័នស្រាវជ្រាវនិង វិស័យឯកជនពិតជាមានសារៈសំខាន់មិនអាចខ្វះបានដើម្បីសម្រេចអនាគតដ៏រុងរឿងមួយសម្រាប់ស្រូវអង្ករកម្ពុជា។

តាមរយៈព្រឹត្តិបត្រនេះយើងខ្ញុំយល់ឃើញថាភាគីពាក់ព័ន្ធក៏ដូចជាសាធារណជននឹងបានជ្រួតជ្រាបនូវសកម្មភាពដែលសហព័ន្ធស្រូវអង្ករកម្ពុជាបានធ្វើដើម្បីរួមចំណែកដល់ការរីកចម្រើនរនៃវិស័យស្រូវអង្ករនៅកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០១៧

ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

**សុខ ពុទ្ធីវុធ**

# 2.បេសកកម្មស្វែងរកទីផ្សារក្រៅប្រទេស និងនិន្នាការប្រែប្រួល















## 2.1 អឺរ៉ុបនៅតែជាទីផ្សារសំខាន់ និងមានសក្តានុពលសម្រាប់ផលិតផលអង្ករកម្ពុជាតែប្រឈមការដាក់កំហិត និង ការតាមដាន

ការនាំចេញអង្ករជាផ្លូវការដំបូងបំផុតរបស់កម្ពុជា គឺការនាំអង្ករទៅទីផ្សារអឺរ៉ុបដែលជាទីផ្សារដ៏មានសក្តានុពល សម្រាប់វិស័យកសិកម្មនៃកម្ពុជា។ ជាលើកដំបូងនៅឆ្នាំ**២០០៨** កម្ពុជាបាននាំអង្ករប្រមាណ៦ពាន់តោនទៅកាន់សហភាពអឺរ៉ុបក្រោយកម្ពុជាចចារបាននូវការនាំចូលទំនិញដោយរួចពន្ធក្រោមគម្រោង **EBA(Everything But Arms)**ក្នុងឋានៈជា ប្រទេសអភិវឌ្ឍន៍តិចតួច **(LDC)**។

ក្នុងរយៈមួយទសវត្សរ៍កន្លងមកនេះអង្ករកម្ពុជាបានសាងកេរ្តិ៍ឈ្មោះយ៉ាងល្អនៅតំបន់អឺរ៉ុបដែលធ្វើអោយការនាំចេញរបស់កម្ពុជាទៅកាន់តំបន់នោះមានកំណើនទាំងបរិមាណនិងតម្លៃ។ ប្រទេសស្ទើរទាំងអស់នៅក្នុងតំបន់អឺរ៉ុបទាំងមូលបានទិញអង្ករកម្ពុជាយកទៅប្រើប្រាស់តាមតម្រូវការ។

ប្រៀបធៀបទៅនឹងប្រទេសអភិវឌ្ឍន៍តិចតួចដ៏ទៃទៀតកម្ពុជាទទួលបានជោគជ័យបំផុត ក្នុងការនាំចេញអង្ករទៅកាន់ទីផ្សារនេះ។ តាមរយៈទិន្នន័យការនាំចេញអង្ករកម្ពុជានៅឆ្នាំ២០១៥ ទៅកាន់ទីផ្សារអឺរ៉ុបមានជាង ៧៧% នៃការនាំចេញសរុបក្រោមគម្រោង **EBA** ខណៈដែលប្រទេសមីយ៉ាន់ម៉ាមានត្រឹមតែ២១%ប៉ុណ្ណោះ ហើយប្រទេសផ្សេងៗទៀតមាន ភាគរយតិចតួចបំផុត។

បើទោះបីជាមានការស្វែងរកទីផ្សារថ្មីៗ បន្ថែមទៀតក៏ដោយការនាំអង្កររបស់កម្ពុជាទៅកាន់ទីផ្សារអឺរ៉ុប នៅតែបន្តឈរលំដាប់កំពូលស្រួបយករហូត ៥៣% នៃបរិមាណនាំចេញសរុបចំនួន **២៨៨,៥៦២** តោន។ ប្រទេសនៅសហភាពអឺរ៉ុប ដែលនាំចូលអង្ករកម្ពុជាច្រើនបំផុតមានចំនួន១០ គឺ **បារាំង ប៉ូឡូញ ចក្រភពអង់គ្លេស ហូឡង់ បែលហ្ស៊ិក អ៊ីតាលី អាឡឺម៉ង់ អេស្ប៉ាញ ស៊ុយអែត ព័រទុយហ្គាល់** ។ បារាំងជាប្រទេសនាំចូលអង្ករពីកម្ពុជាលំដាប់លេខ ១ ផ្អែកលើបរិមាណចំនួន **៣៧,៣២១** តោន ខណៈដែលប្រទេសព័រទុយហ្គាល់នាំចូលអង្ករកម្ពុជា **២,៨៣៧** តោនក្នុងរយៈពេលមួយឆមាសឆ្នាំ២០១៧នេះ។



**រូបភាព** : ឃ្លាំងស្តុកស្រូវមួយនៅប្រទេសកម្ពុជា



**រូបភាព** : ឃ្លាំងស្តុកស្រូវមួយនៅប្រទេសកម្ពុជា

### កត្តាប្រែប្រួលចំពោះទីផ្សារអឺរ៉ុប

សេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្មកាលពីខែធ្នូចុងឆ្នាំ២០១៦ បានឲ្យដឹងថាគណៈកម្មការអឺរ៉ុបនឹងដាក់ឲ្យប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញប្រភេទថ្មីចំពោះការនាំចេញអង្ករកម្ពុជាចូលទៅទីផ្សារអឺរ៉ុបសម្រាប់ឆ្នាំ ២០១៧។ ក្រសួងពាណិជ្ជកម្ម ក៏បានអនុវត្តការប្រើប្រាស់ វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ **(CO)** ប្រភេទថ្មីសម្រាប់ការនាំចេញអង្ករទៅកាន់ទីផ្សារអឺរ៉ុប ឲ្យស្របនឹងតម្រូវការរបស់គណៈកម្មការអឺរ៉ុប ដែលតាមសេចក្តីរាយការណ៍អឺរ៉ុបហាក់មានបំណងតាមដានប្រភពអង្ករដែលបាននាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប ដោយសារកំណើនខ្ពស់ពេកក្នុងឆ្នាំកន្លងមក។

នៅខែមករាឆ្នាំ២០១៧ នាយកដ្ឋាននាំចូល នាំចេញនៃក្រសួងពាណិជ្ជកម្មបានជួបប្រជុំជាលើកដំបូងជាមួយម្ចាស់និងតំណាងក្រុមហ៊ុនអង្ករជាង ៣០ ដើម្បីណែនាំនិងពន្យល់មូលហេតុដែលក្រសួងតម្រូវឲ្យ ក្រុមហ៊ុននាំចេញអង្ករបំពេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមប្រភេទថ្មីសម្រាប់ការនាំចេញអង្ករទៅកាន់ទីផ្សារអឺរ៉ុប។

អ្នកនាំចេញមួយចំនួនបានលើកឡើងថាក្រុមហ៊ុនបញ្ជាទិញ (ដៃគូពាណិជ្ជកម្ម) នៅប្រទេសខ្លះមិនទទួលយកនូវទម្រង់ថ្មីនោះទេព្រោះគេបារម្ភពីការជាប់ពន្ធនៅពេលគេបំពេញតាមទម្រង់ថ្មីនេះ។

# អឺរ៉ុបដាក់កំហិតថ្មី ចំពោះសារធាតុទ្រីហ្ស៊ីក្លាហ្សូល (TRICYCLAZOLE)

ការដាក់កំហិតថ្មីលើកាកសំណល់ថ្នាំគីមីកសិកម្មត្រឹម ០,០១ មីលីក្រាមក្នុង ១គីឡូក្រាមអង្ករ ត្រូវបានអ្នកនាំចេញជាច្រើនយល់ឃើញថានឹងក្លាយជាចំណុចឧបសគ្គមួយទៀតសម្រាប់ការនាំចេញអង្ករទៅកាន់ទីផ្សារអឺរ៉ុប។ នៅខែមីនាឆ្នាំ២០១៧ សហព័ន្ធស្រូវអង្ករកម្ពុជា(**CRF**)និងគម្រោងខ្សែរសង្វាក់កសិកម្មកម្ពុជា(**CAVAC**)បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកដំបូងស្តីពីការប្រើប្រាស់ថ្នាំគីមីកសិកម្មទ្រីហ្ស៊ីក្លាហ្សូល(**TRICYCLAZOLE**)នៅក្នុងការដាំដុះស្រូវដើម្បីត្រៀមរកដំណោះស្រាយថ្មីសម្រាប់និរន្តរភាពកសិកម្មដំណាំស្រូវនិងការនាំចេញអង្ករទៅកាន់ទីផ្សារអឺរ៉ុប។ ក្រុមហ៊ុននាំចេញបានយល់ឃើញថាជាមួយការកម្រិតថ្មីនេះភាពប្រថុយប្រថាននឹងកើតមានកាន់តែកៀកសម្រាប់អង្ករនាំចេញទាំងឡាយណាដែលមិនបានឆ្លងកាត់ការពិសោធន៍ជាមុន។ អ្នកនាំចេញមួយចំនួនបានបង្ហាញពីបំណងមិនទទួលយកកុងត្រាថ្មីព្រោះខ្លួនបារម្ភពីការចាប់ត្រួតពិនិត្យនៅពេលទំនិញទៅដល់កំពង់ផែណាមួយរបស់ប្រទេសណាមួយក្នុងតំបន់អឺរ៉ុបនោះ។



រូបភាព : លោក Patrick Deboyer

## វិធានការឆ្លើយតប

ដើម្បីដោះស្រាយបញ្ហាបន្ទាន់លើការដាក់កំហិតថ្មីនេះនិងដើម្បីរក្សាទីផ្សារអឺរ៉ុបជាទីផ្សារដ៏មានសក្តានុពលសហព័ន្ធស្រូវអង្ករកម្ពុជា បានធ្វើសំណើរជួបពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធជាបន្តបន្ទាប់ដើម្បីចង់ដឹងពីចំណាត់ការរបស់ស្ថាប័នមានសមត្ថកិច្ច និង ការផ្តល់យោបល់ ក៏ដូចជាចូលរួមក្នុងការធ្វើសកម្មភាពដើម្បីលុបបំបាត់ការប្រើប្រាស់ថ្នាំដែលមានសារធាតុ Tricyclazole នោះ។





នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ លោក **នខ ទាសនា** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាបានដឹកនាំបុគ្គលិកលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជានិង សមាជិកសហព័ន្ធជួបពិភាក្សាជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងពាណិជ្ជកម្មដឹកនាំដោយឯកឧត្តម **សុខ សុភ័ត្រ** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។

នាពេលនោះ អង្គប្រជុំបានពិភាក្សាលើ៖

- ស្ថានភាពនៃការនាំចេញ និង ភាពប្រឈម
- សារធាតុគីមីទ្រីហ្ស៊ីក្លាហ្សូល (**Tricyclazole**) និងដំណោះស្រាយក្នុងការនាំចេញ
- លទ្ធភាពតវ៉ាតាមផ្លូវច្បាប់ ឬក៏ស្នើសុំពន្យាការអនុវត្ត
- ការកំណត់ស្រាវជ្រាវថ្នាំកសិកម្មដែលផ្សំពីសារធាតុ Tricyclazole
- យុទ្ធនាការសម្រាប់ការដាំដុះនៅរដូវកាលថ្មីដោយបញ្ចៀសការប្រើប្រាស់ថ្នាំទាំងឡាយណាដែលមានផ្សំពីសារធាតុ Tricyclazole
- កំណត់តំបន់ណាដែលគ្មានការប្រើប្រាស់ឬប្រើប្រាស់តិចតួចនៃសារធាតុ Tricyclazole សម្រាប់នាំចេញទៅកាន់ទីផ្សារអឺរ៉ុប
- កំណត់យកមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់និងអាចរកឃើញសារធាតុTricyclazoleសម្រាប់ធ្វើតេស្តអង្ករមុននាំចេញ។

នៅថ្ងៃទី៤ខែមេសាឆ្នាំ២០១៧ ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា និង សមាជិករបស់ខ្លួន បានជួបប្រជុំជាពិសេសជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកសិកម្មដើម្បីពិភាក្សាការងារសំខាន់ៗ ដែលកំពុងប្រឈមនាពេលបច្ចុប្បន្ននៅក្នុងនោះក៏បានលើកឡើងពីក្តីបារម្ភអំពីការដាក់កំហិតថ្មីរបស់សហភាពអឺរ៉ុបនេះដែរ។

រូបភាព : Tricyclazole first meeting and EU market



## 2.2 អង្ករកម្ពុជាកំពុងពេញនិយមនៅទីផ្សារចិន

ទោះបីការអនុញ្ញាតឲ្យមានការនាំចូលតាមចំនួនកំណត់ (កូតា) ក្តីប៉ុន្តែគុណភាពអង្ករកម្ពុជាទទួលយកបានដោយទីផ្សារនិងប្រជាជនចិនតែម្តង។ ច្បាស់ណាស់ថាបើគ្មានការគាំទ្រពីទីផ្សារឬ អ្នកប្រើប្រាស់ផ្ទាល់នោះទេ ការអនុញ្ញាតឲ្យនាំចូលក៏គ្មានន័យហើយនឹងត្រូវបញ្ចប់ពេលណាមួយដ៏ខ្លី។ ផ្ទុយទៅវិញការគាំទ្ររបស់រដ្ឋាភិបាលនិងប្រជាជនចិនបានធ្វើឲ្យអង្ករកម្ពុជាមានតម្រូវការកើនឡើងជាលំដាប់នៅទីផ្សារប្រទេសចិន។

កម្ពុជាបាននាំចេញអង្ករដំបូងទៅកាន់ប្រទេសចិននៅឆ្នាំ២០១២ ក្រោយការត្រួតពិនិត្យនិងយល់ព្រមពី អគ្គរដ្ឋបាលត្រួតពិនិត្យគុណភាពអធិការកិច្ច និង ចត្តាឡីស័កនៃសាធារណៈរដ្ឋប្រជាមានិតចិន **( AQSIQ)** ប៉ុន្តែការនាំចេញនាពេលនោះគ្រាន់តែជាការនាំចេញសាកល្បងដើម្បីស្ទង់ទីផ្សារតែប៉ុណ្ណោះ។



ឆ្នាំ **២០១៥** និង**២០១៦** រដ្ឋាភិបាលចិនសម្រេចផ្តល់កូតាដល់អង្ករកម្ពុជាក្នុងបរិមាណ **១០**ម៉ឺនតោនក្នុងមួយឆ្នាំហើយចំនួនកូតាត្រូវបានបន្ថែមរហូតដល់ **២០**ម៉ឺនតោន នៅឆ្នាំ២០១៧។ សម្រាប់ឆ្នាំ២០១៨ចិនបានយល់ព្រមតំឡើងកូតារហូត **៣០** ម៉ឺនតោន។

អ្នកនាំចេញសង្ឃឹមថា កម្ពុជានឹងអនុវត្តដោយជោគជ័យសម្រាប់២០ម៉ឺនតោននៅឆ្នាំ២០១៧នេះដោយក្នុងរយៈពេលតែឆមាសទី១ ការនាំចេញអង្ករទៅទីផ្សារចិនសម្រេចបាន **៩៧,៨០០** តោន។ ការនាំចេញមានភាពមមាញឹកបំផុតគឺស្ថិតនៅក្នុងត្រីមាសចុងក្រោយនៃរៀងរាល់ឆ្នាំដោយសារ ការប្រមូលផលស្រូវ។

ក្រោយពីទទួលបានការយល់ព្រមពីភាគីចិនក្នុងការទិញអង្ករកម្ពុជា៣០ម៉ឺនតោនសម្រាប់ឆ្នាំ២០១៨ ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជានិង លោក **ចាន់ សុខនី** អគ្គនាយកក្រុមហ៊ុន Green Trade ដែលជាក្រុមហ៊ុនរដ្ឋបានត្រៀមខ្លួនរួចជាស្រេច ក្នុងការអនុវត្តការនាំចេញ ដោយបានបំពេញទស្សនកិច្ចនៅទីក្រុងប៉េកាំងប្រទេសចិន រយៈពេល៣ថ្ងៃ ពីថ្ងៃទី ៤ដល់ទី៦ ខែកក្កដា ឆ្នាំ២០១៧ ដើម្បីជួបប្រជុំជាមួយក្រុមហ៊ុនរដ្ឋចិន COFCO អំពីបែបបទនៃការនាំចេញសម្រាប់កូតាឆ្នាំ២០១៨។



ក្នុងជំនួបប្រជុំនោះភាគីទាំងពីរបានពិភាក្សាលើរបៀបវារៈចំនួន ៣ រួមមាន:

**១**) ការកែសម្រួល និងបញ្ចូលបញ្ជីឈ្មោះក្រុមហ៊ុននាំចេញសម្រាប់ការអនុវត្តកូតាឆ្នាំ២០១៧

**២** ) ការពិភាក្សាពីផែនការនិងបែបផែនផ្សេងៗ [Models] សម្រាប់អនុវត្តឆ្នាំ២០១៨

**៣** ) កិច្ចសហការស្តីពីការប្រើប្រាស់ម៉ាកសញ្ញាអង្ករកម្ពុជាដែលពេលខ្លះអ្នកប្រើប្រាស់ យល់ច្រឡំដោយកូតាផលិតផលប្រទេសផ្សេងបានក្លែងបន្លំ





ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានចាត់ទុកការបើកនិងពង្រីកទីផ្សារនៅប្រទេសចិន និង ប្រទេសផ្សេងៗទៀត មានសារៈសំខាន់ណាស់ ព្រមទាំងទាមទារការសហការគ្នាល្អក្នុងសង្វាក់ផលិតកម្ម។ ឯកឧត្តម **សុខ ពុទ្ធិវុធ** បានអះអាង៖«យើងត្រូវដើរស្របគ្នាជាមួយមូលដ្ឋាននៃការផលិតរបស់យើង ដែលមានសហគមន៍កសិកម្មជាអ្នកអនុវត្ត ហើយបើយើងអាចទាញយកនូវបច្ចេកវិទ្យាទំនើបៗមកធ្វើកសិកម្ម និងកសិឧស្សាហកម្មនៅកម្ពុជាដែលយើងអាចធ្វើអោយទិន្នផលកាន់តែខ្ពស់ និងអាចកាត់បន្ថយថ្លៃដើមនៃការផលិតបាន»។

ក្នុងដំណើរទស្សនកិច្ចនោះដែរ គណៈប្រតិភូដឹកនាំដោយ ឯកឧត្តម **សុខ ពុទ្ធិវុធ** បានជួបពិភាក្សាជាមួយ លោក **Zhou Xianbiao**, ប្រធានក្រុមហ៊ុនសាជីវកម្មកសិពាណិជ្ជកម្មកសិដ្ឋានរដ្ឋ (Chairman of China State Farms Agribusiness (Group) Corporation) ដោយផ្តោតលើការសហការគ្នារវាងភាគីទាំងពីរ ក្នុងការពង្រីកនិងអភិវឌ្ឍន៍ផ្នែកកសិកម្មនិងកសិឧស្សាហកម្មនៅកម្ពុជា។ ជាមួយគ្នានោះ លោក **Zhou Xianbiao** បានកោតសរសើរអំពីសក្តានុពលវិនិយោគនៅក្នុងប្រទេសកម្ពុជាដែលមានធនធានធម្មជាតិអំណោយផល ស្ថេរភាពនយោបាយល្អ និងកំណើនសេដ្ឋកិច្ចល្អ សម្រាប់ទាក់ទាញអ្នកវិនិយោគ និងការអភិវឌ្ឍន៍ប្រទេសបានឆាប់រហ័ស៕





## ការពង្រីកទំនាក់ទំនងលើវិស័យស្រូវអង្ករ កម្ពុជា-ចិន

កាលពីថ្ងៃទី២៩ខែមិថុនាឆ្នាំ២០១៧ ក្រោមការធ្វើជាសាក្សីពីឯកឧត្តម ឈួន ដារ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ឯកឧត្តម **ចាន់ សុផល** អភិបាលខេត្តបាត់ដំបង និង ឯកឧត្តម Jin Yu Hui អភិបាលរងខេត្តជីលីនរបស់ចិន សហព័ន្ធស្រូវអង្ករកម្ពុជា ក្រុមហ៊ុនសោម៉ាគ្រុប ក្រុមហ៊ុន Jilin Province Investment Co.Ltd និង Jilin Tianzhong Agriculture Development Co. Ltd បានចុះហត្ថលេខាព្រមព្រៀងរួមគ្នាធ្វើការងារលើឃ្លាំងស្តុក និង ឡសម្ងួតស្រូវ ក្នុងខេត្តបាត់ដំបង និង ខេត្តមួយចំនួនទៀត។

ការចុះអនុស្សរណៈយោគយល់គ្នានេះគឺជាការបោះមួយជំហានទៅមុខទៀតដើម្បីធ្វើឲ្យស្ថានភាពស្រូវអង្ករកាន់តែប្រសើរឡើងនៅកម្ពុជា។ កិច្ចព្រមព្រៀងថ្មីនេះនឹងអនុញ្ញាតឲ្យភាគីទាំងពីរអនុវត្តសាកល្បងនូវគម្រោងឃ្លាំងនិងឡសម្ងួតស្រូវ ដែលគេទន្ទឹងរង់ចាំជាយូរមកហើយ មុនឈានទៅអនុវត្តគម្រោងធំដែលមានទំហំទឹកប្រាក់រាប់រយលានដុល្លារអាមេរិកដែលគេតែងតែឮក្នុងពេលកន្លងមក។



**រូបភាព** : សន្និសិទ សេដ្ឋកិច្ចនិងពាណិជ្ជកម្ម ខេត្ត ជីលីន

ក្រោយការចុះហត្ថលេខាលើអនុស្សរណៈនោះ ឧកញ៉ា **ហ៊ុន ឡាក់** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាបានប្រាប់កាសែតភ្នំពេញប៉ុស្តិ៍ថាគម្រោងនឹងត្រូវសិក្សាបញ្ចប់ក្នុងពេលឆាប់ៗហើយស្វែងរកតំបន់សក្តានុពលចំនួនពីរខេត្តគឺខេត្តបាត់ដំបង និងខេត្តតាកែវ។

ពិធីនោះបានរៀបចំឡើង ដោយមានវត្តមានពាណិជ្ជករទាំងពីរប្រទេសជាង១៥០នាក់ ក្នុងនោះ គណៈប្រតិភូនិងអ្នកធុរកិច្ចខេត្តជីលីន ៥៦នាក់ មកពីសហគ្រាសនិងក្រុមហ៊ុន៣២ ព្រមទាំងធុរជនកម្ពុជាជាច្រើនរូប។ ក្រៅពីកិច្ចព្រមព្រៀងខាងលើ ក៏នៅមានអនុស្សារណៈ៥ផ្សេងទៀតបានចុះហត្ថលេខា ដើម្បីបើកផ្លូវទៅរកការពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម។



ខេត្តជីលីនមានប្រជាជនជាង២៧លាននាក់ ស្ថិតនៅភាគឦសាន្តប្រទេសចិនជាប់ព្រំដែនកូរ៉េខាងជើង។ ខេត្តនេះមានសក្តានុពលខាងឧស្សាហកម្ម កសិកម្ម និង សេវាកម្ម។

នាពេលនោះឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហពន្ធ័ស្រូវអង្ករកម្ពុជាបានអះអាងថា៖ «កិច្ចព្រមព្រៀងសហប្រតិបត្តិការលើគម្រោងឃ្លាំងដែលចុះហត្ថលេខានៅថ្ងៃនេះមានគោលបំណងស្វែងរកដំណោះស្រាយលើបញ្ហាស្រូវអង្ករជាពិសេសជួយដល់គ្រប់ភាគីទាំងអស់ក្នុងសង្វាក់ផលិតកម្មស្រូវអង្ករដោយរាប់ទាំងកសិកររោងម៉ាស៊ីននិងអ្នកនាំចេញដោយអាចផ្សារភ្ជាប់អ្នកផលិតរហូតដល់ទីផ្សារ»។

សម្រាប់វិស័យកសិកម្មមានប្រព័ន្ធធារាសាស្ត្រល្អនិង មានប្រភពទឹកជាក់លាក់ ចំណែកឧស្សាកម្មវិញ ខេត្តបាត់ដំបងនឹងមានរោងចក្រស៊ីម៉ង់ត៍ ដែលនឹងដំណើរការនៅខែមករាឆ្នាំ ២០១៨ខាងមុខដែលវិនិយោគដោយក្រុមហ៊ុនចិន៕

ឯកឧត្តម **សុខ ពុទ្ធិវុធ** បានរំឭកថាគំនិតនៃការសង់ឃ្លាំងស្តុកស្រូវនិងឡសម្ងួតនេះត្រូវបានលើកឡើងជារឿយៗនៅតាមសហគមន៍អ្នកសិក្សាអ្នកផលិតស្រូវអ្នករោងម៉ាស៊ីនក៏ដូចអ្នកនាំចេញប៉ុន្តែគេមិនទាន់ធ្វើឲ្យចេញជារូបរាងនៅឡើយ។ ឯកឧត្តម Jin Yu Hui អភិបាលរងខេត្តជីលីន ដែលបានដឹកនាំគណៈប្រតិភូនិងអ្នកធុរកិច្ចចិនមកពីខេត្តនោះបានមើលឃើញពីឱកាសពង្រីកទំនាក់ទំនងពាណិជ្ជកម្ម នៃខេត្តទាំងពីរទៅថ្ងៃអនាគតដោយសារតែចំណងមិត្តភាពដ៏ជិតស្និទ្ធដែលថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានបង្កើតឡើង។




ឯកឧត្តមនិយាយថា៖ «ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះពាណិជ្ជកម្មទ្វេភាគីនិងការវិនិយោគទាំងសងខាងរក្សាកំណើនសន្ទុះខ្លាំងប្រទេសចិនបានក្លាយជាដៃគូពាណិជ្ជកម្មធំបំផុត និងជាប្រទេសដែលមានប្រភពវិនិយោគដ៏ធំបំផុត »។



ឯកឧត្តម **Jin Yu Hui** បានសរសើរ ខេត្តបាត់ដំបងថាជាខេត្តកសិកម្មនិងជាឃ្លាំងស្តុកស្រូវអង្ករដ៏ធំមួយរបស់ប្រទេសកម្ពុជា។ នាពេលនោះឯកឧត្តម **ច័ន្ទ សុផល** អភិបាលខេត្តបាត់ដំបងក៏បានលើកឡើងពី សក្តានុពលរបស់ខេត្តបាត់ដំបងទាំងវិស័យកសិកម្មនិងឧស្សាហកម្ម។

## 2.3. ស្ថានភាពទីផ្សារអង្ករកម្ពុជាក្រៅពី អឺរ៉ុប និង ចិន

ក្រៅពីទីផ្សារធំៗពីរ គឺទីផ្សារអឺរ៉ុបនិង ចិនដែលអ្នកនាំចេញអនុវត្តបានក្រោមការជួយជ្រោមជ្រែងពីផ្នែកពាក់ព័ន្ធមានទាំងស្ថាប័នរដ្ឋនិងដៃគូអភិវឌ្ឍន៍សហព័ន្ធស្រូវអង្ករកម្ពុជាតែងបានរួមចំណែកគិតគូរចំពោះការធ្វើពិពិធកម្មទីផ្សារអង្ករ។ យោងតាមទិន្នន័យនាំចេញ (ដូចបានភ្ជាប់មកនៅទំព័រ ២៤) អង្ករកម្ពុជាមិនត្រឹមតែល្បីល្បាញក្នុងអឺរ៉ុបនិងចិននោះទេថែមទាំងល្បីដែរក្នុងប្រទេសមួយចំនួនក្នុងតំបន់អាស៊ាន អាស៊ី មជ្ឈឹមបូព៌ា ទ្វីបអាមេរិក ទាំងខាងជើង កណ្តាល និង ខាងត្បូង និង ទ្វីបអាហ្វ្រិកផង ។ ប្រទេសក្នុងតំបន់អាស៊ានបាននាំចូលអង្ករជាង ២០០០តោន នៅឆមាសទី១ ឆ្នាំ២០១៧ ខណៈតំបន់មួយចំនួនដែលបានរៀបរាប់ខាងលើបាននាំចូលអង្ករពីកម្ពុជា ៥,៤៨០ តោននៅរយៈពេលដូចគ្នានេះ។



លោក **ហេង ផេង**

**លោក ហេង ផេង** ម្ចាស់ក្រុមហ៊ុនផ្គត់ផ្គង់អង្ករដល់ក្រុមហ៊ុនធំមួយដល់ទីផ្សារក្នុងស្រុកនិងនាំចេញដែលដំណើរការរោងម៉ាស៊ីននៅស្រុកថ្មគោលខេត្តបាត់ដំបងបានប្រាប់ថាក្រុមហ៊ុនរបស់លោក បានចាប់ផ្តើមនាំចេញអង្ករដំបូងទៅកាន់ទីផ្សារប្រទេសម៉ាឡេស៊ីនៅពាក់កណ្តាលឆ្នាំ២០១៤។ ចាប់តាំងពីពេលនោះមកការផ្គត់ផ្គង់អង្ករទៅដៃគូពាណិជ្ជកម្មក្នុងប្រទេសម៉ាឡេស៊ី គឺបានធ្វើឡើងជារៀងរាល់ឆ្នាំ។ សម្រាប់ឆ្នាំ**២០១៧** លោក ហេង ផេង ទទួលបានការបញ្ជាទិញពីភាគីម៉ាឡេស៊ីរហូតដល់ទៅ **៨០០០តោន** ដែលបានចុះកុងត្រារួច។ **លោក ហេង ផេង** យល់ពី «ទីផ្សារម៉ាឡេស៊ីមានតម្រូវការខ្ពស់សម្រាប់អង្ករក្រអូបកម្ពុជាហើយការនាំចូលរបស់ម៉ាឡេស៊ីគឺសម្រាប់លក់ចែកចាយដល់ទីផ្សារក្នុងស្រុករបស់ខ្លួន»។

ម៉ាឡេស៊ីមានតម្រូវការខ្ពស់ចំពោះអង្ករផ្កាម្លិះនិង អង្ករសែនក្រអូបខណៈតម្លៃនាំចេញទៅកាន់ទីផ្សារម៉ាឡេស៊ីអាចទទួលយកបានសម្រាប់ការធ្វើពាណិជ្ជកម្មក្នុងពេលកន្លងមក។ ក្នុងរយៈពេលបីឆ្នាំដែលលោកផ្គត់ផ្គង់ដល់ដៃគូពាណិជ្ជកម្មក្នុងប្រទេសម៉ាឡេស៊ីប្រទេសនេះគេនៅតែបញ្ជាទិញរហូតមកទាំងបរិមាណនិងកោតសរសើរពីគុណភាពអង្កររបស់កម្ពុជា។ លោកយល់ថា «បើសិនជាអង្ករថៃមានតម្លៃខ្ពស់ពេក ម៉ាឡេស៊ីនឹងមកទិញអង្ករពីកម្ពុជាច្រើនដោយសារគុណភាពល្អ និង មានតម្លៃសមរម្យ។ កាលពីឆ្នាំមុន អង្ករថៃថោកទើបម៉ាឡេស៊ីងាកទៅទិញអង្ករពីថៃច្រើន»។



ឧកញ៉ា **ហ៊ុន ឡាក់**

**ឧកញ៉ា ហ៊ុន ឡាក់** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជានិង ជាអគ្គនាយកនៃក្រុមហ៊ុនមេគង្គអូរីហ្សា ដែលធ្លាប់នាំអង្ករចេញទៅកាន់ប្រទេសកូឌីវ័រក្នុងទ្វីបអាហ្វ្រិកតាមរយៈក្រុមហ៊ុនមួយផ្សេងទៀតដែលមានទំនាក់ទំនងក្នុងប្រទេសនោះបានអះអាងថាជំនួញអង្ករទៅកាន់ទីផ្សារ អាហ្វ្រិកពិបាកឲ្យរីកធំធាត់លឿនណាស់ដោយសារអ្នកនាំចេញជាច្រើនដាក់កង្វល់នៅចំពោះមុខរួចទៅហើយអំពីឧបសគ្គនានាកើតចេញពីតំបន់អាហ្វ្រិក។ ឧបសគ្គទាំងនោះមានផ្លូវឆ្ងាយការដឹកជញ្ជូនមានឧបសគ្គច្រើននិង រឿងសំខាន់បំផុត គឺការទូទាត់លុយ និង ការបោកប្រាស់។

**ឧកញ៉ា** បានបញ្ជាក់ថា ៖«អ្នកនាំចេញឬក្រុមហ៊ុនរបស់កម្ពុជាមិនអាចនាំចេញដោយត្រង់ៗទៅអាហ្វ្រិកបានទេបើមិនដូច្នេះគេនឹងប្រឈមហានិភ័យខ្ពស់។កន្លងមកមានក្រុមហ៊ុនខ្លះទម្លាក់ទំនិញចូលកប៉ាល់និងដឹកចេញរួចហើយតែចុងក្រោយត្រូវឲ្យដឹកទំនិញអង្ករត្រឡប់វិញ ព្រោះតែការទូទាត់លុយមិនបានធ្វើឡើងតាមកិច្ចព្រមព្រៀង»។

# 3. សកម្មភាពសម្របសម្រួលបែបបទចូលទីផ្សារ

## 3.1. ការខិតខំដើម្បីចុះបញ្ជីម៉ាកអង្ករនៅក្រសួងពាណិជ្ជកម្ម និង អន្តរជាតិ

ការប្រឹងប្រែងចុះបញ្ជីម៉ាកអង្ករកម្ពុជាគឺជាមធ្យោបាយដ៏សំខាន់បំផុតដែលសហព័ន្ធស្រូវអង្ករកម្ពុជាប្រឹងប្រែងដើម្បីធ្វើទីផ្សារនៅអន្តរជាតិ។ ជានិច្ចកាលសហព័ន្ធស្រូវអង្ករកម្ពុជានៅតែទទូចចង់បានការចុះបញ្ជីថ្នាក់ជាតិ រួចហើយសហព័ន្ធនឹងយកឈ្មោះនោះទៅចុះបញ្ជីជាលក្ខណៈអន្តរជាតិ ដើម្បីងាយស្រួលធ្វើទីផ្សារឲ្យអតិថិជននៅលើពិភពលោកងាយទទួលស្គាល់ចំណាំ និង ងាយចងចាំ ។



ការតស៊ូមតិជាច្រើនឆ្នាំ ការជួបប្រជុំជាច្រើនលើកក្នុងន័យទាមទារការចុះឈ្មោះអង្ករកម្ពុជាមួយគឺដើម្បីរួមចំណែកដល់ការធ្វើទីផ្សារទាំងកម្រិតជាតិនិងថ្នាក់អន្តរជាតិ។

កាលពីថ្ងៃទី០៥ ខែមិថុនា២០១៧ នៅទីស្តីការក្រសួងពាណិជ្ជកម្មមានកិច្ចប្រជុំពិភាក្សាយ៉ាងស៊ីជម្រៅមួយទៅលើម៉ាកអង្ករកម្ពុជាដែលមានឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជានិង ឯកឧត្តម **សុខ សុភ័ត្រ្ត** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មព្រមទាំងមានការចូលរួមដោយ លោក អ៊ុក ម៉ាការ៉ា នាយកវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កម្មកម្ពុជា (CARDI) និង លោក ងិន ឆាយ ប្រធាននាយកដ្ឋានដំណាំស្រូវនៃអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និង នេសាទ។ កិច្ចប្រជុំបានផ្តោតសំខាន់ទៅលើឈ្មោះអង្ករកម្ពុជា ដែលមានសំណើរឈ្មោះ **ម្លិះអង្គរ** ឬជាភាសាអង់គ្លេស MALYS ANGKOR នៅក្នុងកិច្ចប្រជុំនោះ ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាបានស្នើឲ្យក្រសួងពាណិជ្ជកម្មឲ្យពន្លឿនការងារចុះបញ្ជីវិញ្ញាតកម្ម (Certification Mark) សម្រាប់អង្ករកម្ពុជា ដើម្បីលើកកម្ពស់ទីផ្សារនៅអន្តរជាតិ ខណៈពេលនេះកម្ពុជាមិនទាន់មានភាពច្បាស់លាស់ចំពោះម៉ាកសញ្ញាណាមួយជាក់លាក់ដើម្បីផ្សព្វផ្សាយលក់ទៅកាន់ដៃគូពាណិជ្ជកម្មនៅកម្រិតអន្តរជាតិនៅឡើយ។ ការដាក់ម៉ាកអង្ករកម្ពុជា 'អង្ករម្លិះ' នេះគឺដោយយោងទៅលើប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាដែលមានប្រវត្តិជាប្រទេសកសិកម្មដ៏យូរលង់ណាស់មកហើយ។ ម្យ៉ាងទៀតឈ្មោះនេះផ្តល់ភាពងាយចងចាំងាយស្រួលអានរបស់អតិថិជនប្រើប្រាស់ចុងក្រោយ។

ឯកឧត្តម **សុខ ពុទ្ធិវុធ** បានលើកឡើងថា៖ «យើងចង់បានឈ្មោះមួយដែលគ្របដណ្តប់ឈ្មោះអង្ករក្រអូបទាំងអស់ដែលនាំមកនូវភាពជោគជ័យសម្រាប់កម្ពុជានៅទីផ្សារអន្តរជាតិ។ យើងចង់ប្រើពាក្យដែលអ្នកប្រើប្រាស់ងាយយល់ងាយចងចាំងាយនឹកឃើញហើយយើងដាក់" **អង្គរ** "ពីមុខ គឺបញ្ជាក់នូវភាពអស្ចារ្យមានជោគជ័យ ភាពរុងរឿង ហើយសម័យអង្គររុងរឿងដោយសារកសិកម្មល្អដែរ»។

ឯកឧត្តម បានបន្ថែមថា៖ *«ការប្រើពាក្យផ្សេងៗទៀតបារម្ភថា វាមិនទាក់ទាញអ្នកប្រើប្រាស់មករកផលិតផលរបស់យើង ព្រោះថាការប្រើពាក្យម្លិះនេះបានគ្របដណ្តប់លើអង្ករប្រណិតផ្សេងៗទៀតរួចទៅហើយ ។ ឈ្មោះដែលបានស្នើនេះជាឈ្មោះសម្រាប់ធ្វើទីផ្សារសុទ្ធសាធហើយបើទីផ្សារចាប់មិនបាន គឺពូជដែលខិតខំផលិតបានល្អទាំងប៉ុន្មាននឹងអត់ប្រយោជន៍ដល់សេដ្ឋកិច្ច»។*






## 3.2. ការរៀបចំយុទ្ធសាស្ត្រផ្គត់ផ្គង់អង្ករឲ្យមានប្រសិទ្ធភាពដល់ទីផ្សារចិន

រូបមន្តនៃការនាំចេញគឺជាចំណុចឈ្នះសម្រាប់ទាំងអស់គ្នាជាពិសេសបំផុតនោះគឺអ្នកនាំចេញនិងម្ចាស់រោងម៉ាស៊ីន។ សហព័ន្ធស្រូវអង្ករកម្ពុជាដែលដឹកនាំដោយឯកឧត្តម **សុខ ពុទ្ធិវុធ** ជានិច្ចកាលបានផ្តោតការយកចិត្តទុកដាក់ជាទីបំផុតចំពោះការបង្កើតរូបមន្តមួយដែលអ្នកនាំចេញទាំងអស់ឬថា អ្នកនាំចេញភាគច្រើនទទួលយកនិងអនុវត្តបាន។ សហព័ន្ធស្រូវអង្ករកម្ពុជាគឺជាស្ថាប័នតែមួយគត់ធ្វើការសម្របសម្រួលបែបផែនសម្រាប់ការនាំចេញដើម្បីធានាថាការនាំចេញមានប្រសិទ្ធភាពខ្ពស់ និងឆ្លើយតបតាមតម្រូវការទីផ្សារ។

រហូតមកដល់ពេលនេះការនាំចេញអង្ករពីកម្ពុជានៅតែមានឧបសគ្គដោយសារការមិនទាន់បង្កើតបានរូបមន្តណាមួយជាក់លាក់ ឬ អាចនិយាយបានថា «ភាពសម្បូរបែបនៃគំនិត និង ការមិនទទួលយកគំនិតអ្នកដទៃ» បានបង្កជាឧបសគ្គខ្លាំងដល់ការឯកភាពគ្នាលើចំណុចណាមួយសម្រាប់អនុវត្ត។ ប្រការនេះបានបង្កដល់ការប្រកួតប្រជែងផ្ទៃក្នុងការចាប់យកទីផ្សារមិនបានបរិមាណច្រើន បាត់បង់ភាពប្រកួតប្រជែងនិងឧត្តមភាពអង្ករខ្មែរជាដើម។ សហព័ន្ធស្រូវអង្ករកម្ពុជាបានប្រជុំជាញឹកញាប់បំផុតជាមួយក្រុមហ៊ុននិង រោងម៉ាស៊ីនដើម្បីបញ្ច្រាបលក្ខណៈនានាសម្រាប់នាំចេញប្រកបដោយប្រសិទ្ធភាព។

ការប្រជុំលើកចុងក្រោយ គឺនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ជាពេលដែលសហព័ន្ធស្រូវអង្ករកម្ពុជាបានរៀបចំកិច្ចប្រជុំដ៏សំខាន់មួយផ្តោតលើការត្រៀមខ្លួននិងរៀបចំយុទ្ធសាស្ត្រ កិន កែច្នៃស្រូវអង្ករ និង ការផ្គត់ផ្គង់ទីផ្សារប្រកបដោយប្រសិទ្ធភាពនៅឆ្នាំខាងមុខ ស្របពេលដែលរាជរដ្ឋាភិបាលបានស្នើសុំភាគីចិនបង្កើនកូតានាំចេញអង្ករពី ២០ម៉ឺនតោន ក្នុងឆ្នាំ ២០១៧ ទៅ ៣០ម៉ឺនតោន សម្រាប់ឆ្នាំ២០១៨។

កិច្ចប្រជុំនេះបានរៀបចំឡើងដោយលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជានិងមានការអញ្ជើញចូលរួមពីម្ចាស់និងតំណាងរោងម៉ាស៊ីន ក្រុមហ៊ុននាំចេញអង្ករទៅកាន់ទីផ្សារប្រទេសចិនទាំង២៦ ក្រោមអធិបតីភាពឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និង អនុប្រធានក្រុមប្រឹក្សាភិបាលពីររូបគឺ ឧកញ៉ា វង្ស ប៊ុនហេង និង លោក នង វាសនា។



ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាបានស្នើសុំឲ្យរោងម៉ាស៊ីនកិនស្រូវ- ក្រុមហ៊ុននាំចេញអង្ករទៅកាន់ទីផ្សារចិនទាំង២៦ ដែលទទួលស្គាល់ដោយមន្ត្រីAQSIQ របស់ភាគីចិន (General Administration of Quality Supervision, Inspection and Quarantine) សហការគ្នានាំចេញឲ្យបានល្អដើម្បីផ្គត់ផ្គង់ទីផ្សារដែលខិតខំរកបាន។

លោក **មូល សារិទ្ធី** អគ្គលេខាធិការសហព័ន្ធស្រូវអង្ករកម្ពុជាបានរាយការណ៍ជូនអង្គប្រជុំថារហូតមកដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ការនាំចេញអង្ករទៅកាន់ទីផ្សារប្រទេសចិនសម្រេចបាន ៨៦000 តោន ប៉ុន្តែកម្ពុជាបាននាំចេញលើសចំនួនកូតាប្រមាណ ២ម៉ឺនតោន កាលពីឆ្នាំ២០១៦។ តាមរយៈបរិមាណនេះ កម្ពុជានឹងត្រូវនាំអង្ករចេញទៅកាន់ប្រទេសចិនជាង ៩ម៉ឺនតោនបន្ថែមទៀតសម្រាប់កូតាឆ្នាំ២០១៧ នេះ។



លោក **មូល សារិទ្ធី**

ឯកឧត្តម ប្រធានសហព័ន្ធបានបន្ថែមថា កាលពីឆ្នាំ២០១៦ ក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតនាំចេញទៅចិនមានជាង ៤០ ក្រុមហ៊ុនប៉ុន្តែមានតែក្រុមហ៊ុនប្រហែល១០ប៉ុណ្ណោះដែលទទួលបានការបញ្ជាទិញនិងអាចដំណើរការនាំចេញ។ ឯកឧត្តម បញ្ជាក់ថា៖ «យើងនឹងរៀបចំការងារនេះទៅមុខហើយរៀបចំយ៉ាងដូចម្តេចដើម្បីឲ្យមានភាពច្បាស់លាស់សម្រាប់ធានាគុណភាព សុវត្ថិភាព និង បរិមាណនាំចេញ»។ នៅក្នុងឱកាសនោះដែរ ឯកឧត្តមប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាក៏បានលើកឡើងពីការចូលរួមប្រមូលទិញស្រូវក្នុងរដូវប្រមូលផលស្រូវសែនក្រអូបគឺជាគន្លឹះសំខាន់ ដែលអាចជួយឲ្យស្ថានភាពស្រូវអង្ករកាន់តែប្រសើរ និង ផ្តល់ក្តីសង្ឃឹមដល់កសិករ ព្រមទាំងបង្កើតផលចំណេញសម្រាប់វិស័យសេដ្ឋកិច្ចជាតិ។ លើសពីនេះទៀតសហព័ន្ធស្រូវអង្ករនឹងរៀបចំផែនការសម្រាប់ចុះជួបជាមួយសហគមន៍ដើម្បីបញ្ជាក់ពីអ្វីដែលទីផ្សារត្រូវការ។

## 3.3. សម្រួលការចុះត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានកសិកម្ម (GDA) ទៅលើរោងម៉ាស៊ីនកិនស្រូវជាសមាជិក

ការនាំចេញទៅកាន់ប្រទេសចិនបានលុះត្រាតែផលិតផលអង្ករកម្ពុជាត្រូវឆ្លងកាត់ការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីមន្ត្រីត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័កសាធារណរដ្ឋប្រជាមានិតចិន (AQSIQ) និង អគ្គនាយកដ្ឋានកសិកម្មកម្ពុជា (GDA)។ ក្នុងដំណើរការត្រួតពិនិត្យនេះ សហព័ន្ធស្រូវអង្ករកម្ពុជាមានតួនាទីសំខាន់បំផុត គឺសម្របសម្រួលសមាជិករបស់ខ្លួន ដូចជាការជូនដំណឹងពីការចុះពិនិត្យ ការរៀបចំបញ្ជីឈ្មោះសមាជិក ការបញ្ជូនឈ្មោះសមាជិកទៅកាន់អគ្គនាយកដ្ឋានកសិកម្ម និង ការចុះផ្ទាល់ជាមួយគណៈប្រតិភូត្រួតពិនិត្យ ទៅកាន់ទីតាំងរោងម៉ាស៊ីន។

សហព័ន្ធស្រូវអង្ករកម្ពុជា ធ្វើការសម្របសម្រួលដើម្បីធានាថា សមាជិករបស់ខ្លួនទទួលបានឱកាសក្នុងការរួមចំណែកនាំចេញអង្ករទៅកាន់ទីផ្សារចិន ដែលជាទីផ្សារមានតម្រូវការច្រើនប្រកបដោយសក្តានុពល។ កាលពីថ្ងៃទី២៨ខែវិច្ឆិកាដល់ថ្ងៃទី១៣ ក្នុងខែធ្នូឆ្នាំ២០១៦ អគ្គត្រួតពិនិត្យគុណភាព អធិការកិច្ចនិងចត្តាឡីស័កសាធារណរដ្ឋប្រជាមានិតចិន(AQSIQ) បានចុះមកត្រួតពិនិត្យរោងម៉ាស៊ីននិងក្រុមហ៊ុនចំនួន២៦ ដោយផ្ទាល់សម្រាប់នាំចេញទៅកាន់ទីផ្សារចិនតាមកូតា ២០ម៉ឺនតោន បន្ទាប់ពីអគ្គនាយកដ្ឋានកសិកម្មបញ្ជូនឈ្មោះរោងម៉ាស៊ីនចំនួន ២៨ ដោយស្រង់ចេញពីចំនួនរោងម៉ាស៊ីនសរុប ៤៧ ដែលបានស្នើនាពេលនោះ។

ក្រោយការសម្រេចរោងម៉ាស៊ីន ២៦ មានសិទ្ធិនាំចេញទៅកាន់ទីផ្សារចិន មានក្រុមហ៊ុននិង រោងម៉ាស៊ីនជាច្រើនយ៉ាងហោចណាស់ជាង ៥០ ដែលដាក់ពាក្យមកកាន់សហព័ន្ធស្រូវអង្ករកម្ពុជា ដោយស្នើឲ្យមានការចុះត្រួតពិនិត្យជាថ្មីដើម្បីបើកឱកាសឲ្យខ្លួនបាននាំចេញអង្ករទៅកាន់ប្រទេសចិនដែរ។ ក្រោយពីទទួលបានការស្នើសុំជាបន្តបន្ទាប់និងមានចំនួនកាន់តែច្រើនឡើងៗ សហព័ន្ធស្រូវអង្ករកម្ពុជាបានជួបប្រជុំជាញឹកញាប់ដើម្បីសម្របសម្រួលសមាជិករបស់ខ្លួនក្នុងន័យឲ្យមានការចូលរួមចំណែកកែច្នៃផលិតផលអង្ករសម្រាប់នាំចេញរួមគ្នា។ ជាមួយបរិមាណកូតាថ្មីដែលនឹងកើនដល់ ៣០ម៉ឺនតោនសម្រាប់ឆ្នាំ២០១៨ ខាងមុខសហព័ន្ធស្រូវអង្ករកម្ពុជាដឹងច្បាស់ថាការរួមគ្នាផលិតកែច្នៃនិងផ្គត់ផ្គង់អង្ករ គឺជាការចាំបាច់បំផុតដើម្បីសម្រេចគោលដៅនាំចេញឲ្យបានកាន់តែច្រើន។

បទពិសោធន៍ដែលអនុញ្ញាតឲ្យក្រុមហ៊ុនតែ២៦មានសិទ្ធិកែច្នៃសម្រាប់នាំចេញបានផ្តល់ផលលំបាកខ្លះៗមកហើយដូចជាតម្លៃដើមអង្ករបានកើនឡើងខ្ពស់ព្រោះត្រូវនាំយកអង្ករទៅកាន់រោងម៉ាស៊ីនដែលមានសិទ្ធិសម្រាប់វេចខ្ចប់ និងឆ្លងកាត់ការត្រួតពិនិត្យ ដោយមិនត្រឹមតែការចំណាយកើនឡើងនោះទេ សូម្បីការផ្គត់ផ្គង់ និង ការដឹកជញ្ជូនក៏មានការលំបាកជាងការអនុវត្តកន្លងមកដែរ។



ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជានិងលោក **ចាន់ សុខឌី** អគ្គនាយកក្រុមហ៊ុនរដ្ឋហ្គ្រីនត្រេដ ដែលជាសហគ្រាសរដ្ឋតែងតែយកចិត្តទុកដាក់ក្នុងការសម្របសម្រួលប្រមូលមតិយោបល់ពីម្ចាស់រោងម៉ាស៊ីន និងក្រុមហ៊ុននាំចេញជាសមាជិកដើម្បីទៅជជែកជាមួយភាគីចិន ដែលតំណាងដោយក្រុមហ៊ុនCOFCO ដែលជាសហគ្រាសរបស់រដ្ឋចិន។

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ឯកឧត្តម **សុខ ពុទ្ធិវុធ** និង លោក **ចាន់ សុខឌី** បានបើកកិច្ចប្រជុំលើកដំបូងជាមួយម្ចាស់ក្រុមហ៊ុន និងតំណាងក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតឲ្យនាំចេញទៅកាន់ទីផ្សារចិនសម្រាប់កូតា ២០មុឺនតោន ក្នុងឆ្នាំ២០១៧។ នាពេលនោះ ឯកឧត្តម **សុខ ពុទ្ធិវុធ**ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានមានប្រសាសន៍ថា ការអនុវត្តអនុស្សរណៈនេះពិតជាមានសារៈសំខាន់ ដើម្បីឆ្លុះបញ្ចាំងពីសមត្ថភាពនាំចេញរបស់កម្ពុជា ទៅកាន់ទីផ្សារប្រទេសចិន។ ក្រុមហ៊ុនចំនួន១៨ទទួលបានសិទ្ធិនាំចេញទៅកាន់ប្រទេសចិន តែជាបទពិសោធន៍ក្នុងពេលកន្លងមក មានតែក្រុមហ៊ុន៤ទៅ៥ប៉ុណ្ណោះដែលសកម្មក្នុងការនាំចេញទៅកាន់ទីផ្សារប្រទេសចិន។

ក្នុងការអនុវត្តកូតាឆ្នាំ២០១៧ ក្រុមហ៊ុនរដ្ឋចិន COFCO បានសម្រេចយកក្រុមហ៊ុននាំចេញចំនួន ១៨ សម្រាប់នាំចេញទៅកាន់ទីផ្សារចិនដោយផ្ទាល់បន្ទាប់ពីមានការស្នើសុំពីសហព័ន្ធស្រូវអង្ករកម្ពុជា និង ក្រុមហ៊ុនហ្គ្រីនត្រេដ។

ឯកឧត្តម **សុខ ពុទ្ធិវុធ** បានលើកឡើងថា៖«ទីផ្សារមិនដែលនៅស្ងៀមនោះទេ ពេលខ្លះអ្នកទិញមានប្រៀបជាង ហើយពេលខ្លះទៀតអ្នកលក់ក៏មានប្រៀបខ្លាំងជាងដែរ»។ នាពេលនោះ ឧកញ៉ា **ហ៊ិន ឡាក់** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាបានលើកឡើងថា ការនាំចេញទៅកាន់ទីផ្សារចិននៅតែលំបាក ស្របពេលតម្លៃដើមផលិតអង្ករនៅកម្ពុជាមានរហូតដល់ ៤០៨ ទៅ ៤១០ដុល្លារក្នុងមួយតោន ប៉ុន្តែ ក្រុមហ៊ុនរដ្ឋចិន COFCO ផ្តល់តម្លៃត្រឹមតែ ៤០០ដុល្លារប៉ុណ្ណោះក្នុង១តោនសម្រាប់ប្រភេទអង្ករស។



## ការសម្របសម្រួលម្ចាស់ក្រុមហ៊ុននិងរោងម៉ាស៊ីនជួបប្រជុំជាមួយអគ្គនាយកដ្ឋានកសិកម្ម ដើម្បីស្វែងយល់ពីនីតិវិធីនាំចេញ និង លក្ខខណ្ឌតម្រូវ (ភូតគាមអនាម័យ)

នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ សហព័ន្ធស្រូវអង្ករកម្ពុជាបានសម្របសម្រួលម្ចាស់និងតំណាងរោងម៉ាស៊ីន និង ក្រុមហ៊ុនជិត ៦០នាក់ ក្នុងចំណោមជាង ៧០នាក់ ដើម្បីចូលរួមសិក្ខាសាលាស្តីពី លក្ខខណ្ឌតម្រូវអនាម័យ និងភូតគាមអនាម័យក្នុងការផលិតកែច្នៃ ទុកដាក់អង្ករដើម្បីនាំចេញទៅកាន់ប្រទេសចិន ដែលរៀបចំឡើងដោយអគ្គនាយកដ្ឋានកសិកម្ម។ សិក្ខាសាលានោះបានប្រព្រឹត្តិទៅក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន វណ្ណហាន ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកកសិកម្ម ដោយគោលបំណងលើកកម្ពស់សមត្ថភាពដល់បណ្តាក្រុមហ៊ុនដែលមានបំណងនាំចេញអង្ករទៅកាន់ប្រទេសចិន៕

## 4. ការផលិតស្រូវតម្រូវទីផ្សារ

**តើការដាំដុះស្រូវរបស់យើងឆ្លើយតបចំពោះទីផ្សារនាំចេញហើយឬនៅ?** ត្រង់ចំណុចនេះអ្នកជំនាញជាច្រើននៅមិនទាន់ផ្តល់ចម្លើយជាក់លាក់ណាមួយចំពោះស្ថានភាពស្រូវអង្ករនៅកម្ពុជានៅឡើយទេ។ ព័ត៌មានអំពី ការប្រើប្រាស់ពូជ ទំហំដីដាំដុះ ស្ថានភាពដាំដុះ បច្ចេកទេសដាំដុះ និង ទិន្នផលរំពឹងទុក សម្រាប់ឆ្លើយតបនឹងទីផ្សារ គឺស្ថិតនៅភាពមិនច្បាស់លាស់នៅឡើយ។

### តើសហព័ន្ធធ្វើអ្វីដើម្បីឆ្លើយតបចំពោះបញ្ហានេះ?

តាំងពីក្នុងអាណត្តិទី១ មកម្ល៉េះ ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានមើលឃើញនូវភាពប្រឈមមួយចំនួនទើបផ្តួចផ្តើមឲ្យមាន ការបង្កើតតំណាងតាមតំបន់ ដើម្បីធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយកសិករ។

រហូតដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ គឺ ១០ថ្ងៃក្រោយការបោះឆ្នោតក្រុមប្រឹក្សាភិបាលសហព័ន្ធអាណត្តិទី២ ក្រុមប្រឹក្សាភិបាលបានសម្រេចយល់ព្រមដោយការលើកដៃចំពោះសំណើរបស់ឯកឧត្តមប្រធានសហព័ន្ធ ដើម្បីរៀបចំឲ្យមានតំណាងប្រចាំតំបន់ ដើម្បីធ្វើការងារនៅក្នុងតំបន់ឲ្យមានប្រសិទ្ធិភាព ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសមាជិកនិងអង្គការពាក់ព័ន្ធ ព្រមទាំងផ្សព្វផ្សាយព័ត៌មានឲ្យបានរហ័ស។

បន្ទាប់ពីការគាំទ្រផ្ទៃក្នុង ឯកឧត្តម ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានលើកសំណើនេះទៅកាន់ស្ថាប័នពាក់ព័ន្ធនានាឲ្យគាំទ្រការបែងចែកតំបន់សម្រាប់ជំរុញផលិតកម្មស្រូវនិងប្រសិទ្ធភាពទំនាក់ទំនង។

ក្រោយការយល់ព្រមក្នុងកិច្ចប្រជុំក្រុមការងារផ្នែកស្រូវ-អង្ករនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ និង ការសម្រេចយល់ព្រមរបស់ទីស្តីគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ ស្របតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦ ដែលអនុញ្ញាតឲ្យបង្កើតក្រុមការងារសម្របសម្រួលថ្នាក់តំបន់និងថ្នាក់ខេត្តដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនិង ការងារស្រូវអង្ករនៅមូលដ្ឋាន សហព័ន្ធស្រូវអង្ករកម្ពុជាបានដំណើរការជ្រើសរើសអ្នកសម្របសម្រួលថ្នាក់តំបន់បានចំនួន៣ក្នុងចំណោមតំបន់ទាំង៥ដែលគ្រោងបង្កើតឡើង ហើយសហព័ន្ធកំពុងពិនិត្យអ្នកមានសក្តានុពល មានបទពិសោធន៍ និង មានឆន្ទៈខ្ពស់ក្នុងការងារស្រូវអង្ករសម្រាប់បំពេញការងារនៅតំបន់ទាំងពីរផ្សេងទៀតដែលនៅសេសសល់។



# រចនាសម្ព័ន្ធតាមតំបន់៖

*ក្រោយទទួលបានការគាំទ្រជាផ្លូវការ សហព័ន្ធស្រូវអង្ករកម្ពុជាបានពន្លឿនការងារជ្រើសរើសមន្ត្រីប្រចាំតំបន់ដែលខ្លួនបានរៀបចំឡើង ហើយខាងក្រោមនេះជាបុគ្គលិកប្រចាំតំបន់ដែលបានសម្រេចជាផ្លូវការ៖*


លោក គុន អុល

## ស្វែងយល់ពីការងាររបស់តំបន់១

( ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តព្រះសីហនុនិងខេត្តកែប )

សហព័ន្ធស្រូវអង្ករកម្ពុជាបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការ ផ្សាភ្ជាប់ខ្លួនជាមួយសហគមន៍នៅមូលដ្ឋាន។ ជាមួយទស្សនៈវិស័យរយៈពេលវែង សហព័ន្ធកំពុងលើកទឹកចិត្តដល់សហគមន៍នៅមូលដ្ឋានចូលជាសមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីបើកលទ្ធភាពឲ្យមន្ត្រីប្រចាំតំបន់របស់សហព័ន្ធបានធ្វើការងារជាមួយដោយការយល់ចិត្ត និងសហការល្អ។



លោក **គុន អុល** អ្នកសម្របសម្រួលតំបន់១ ដែលមានប្រាំមួយខេត្តរួមមាន ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តព្រះសីហនុនិងខេត្តកែប។ ក្នុងជំហានដំបូងលោក **គុន អុល** បានផ្តល់អាទិភាពចំពោះការអនុវត្តការងាររបស់ខ្លួនយ៉ាងសកម្មក្នុងខេត្តចំនួនបីរួមមានៈ ខេត្តតាកែវ ខេត្តកំពត និងខេត្តកំពង់ស្ពឺ។ សម្រាប់គោលការណ៏ដែលសហព័ន្ធអនុវត្តន៏អោយមានថ្នាក់តំបន់ប្រចាំខេត្តគឺ ដើម្បីអនុវត្តន៏ផែនការធំៗចំនួន បួន ៖

**ទី១)** ការជ្រើសរើសរោងម៉ាស៊ីនអោយចូលជាសមាជិករបស់សហព័ន្ធនៅតាមខេត្ត
